សម្លេងខ្មែរនៅបរទេស

# មហានគរខ្មែរ កំពុងតែរស់ឡើងវិញ !

ដោយ សុទ្ធ-ប៉ូលិន ★ ថ្ងៃទី៣១ សីហា ២០០៥

ក្នុងបច្ចុប្បន្ននេះ ជនជាតិសៀមក្តី, យួនក្តី សុទ្ធសឹងតែជាជនភាគតិចនៅក្នុងប្រទេសរបស់ខ្លួនឯង, ចំណែកជនភាគច្រើនលើសលប់ គឺសុទ្ធសឹងតែជាជនជាតិខ្មែរ ។ ពួកជនព្រៃភ្នំនៅវៀតណាមកណ្តាល ដែលកំពុងមានទំនាស់ជាមួយរដ្ឋការហាណូយ គឺសុទ្ធសឹងតែជាពួកខ្មែរលើ (នគរចាមកាលពីសម័យអតីតកាលមានឈ្មោះថា «នគរពិជ័យ») ។ ចំណែកប្រទេសភូមាវិញ យើងមិនបាច់នឹងថ្លែងទេ គឺជាប្រទេសខ្មែរ-មនសុទ្ធសាធ (សព្វថ្ងៃនេះភូមាដូរមកឈ្មោះដើមវិញជា «មីអង្គម៉ា» ឬ «ព្រះអង្គម៉ែ»មានន័យដូច«ខ្មែរ» គឺជាទឹកដីដែលព្រះម៉ែបានចងដៃ.. ដោយជនជាតិខ្មែរដើមគ្រប់ទីកន្លែងទុកមេបាជាព្រះបង្កើតលោក ។ នៅទីបំផុតប្រទេសម៉ាឡេ ឬម៉ាឡាយូ, ម៉ាឡៃ ឬមេឡៃ ក៏មានន័យដើមថា «ម៉ែអាល័យ» ឬ «ព្រះម៉ែចងដៃ» ដូចប្រទេសខ្មែរដែរ («ព្រះ»ស្រង់ន័យដើមពីពាក្យខ្មែរ «បារះ» ឬព្រះអាទិត្យជាឋានសួគ៌ ឋានសុវណ្ណ បើគ្មានព្រះអាទិត្យដែលផ្តល់ពន្លឺនិងកំដៅនោះទេ ជីវិតសត្វលោកនឹងត្រូវវិនាសសាបសូន្យ... ព្រះអាទិត្យឬព្រះសូរ្យត្រូវប្រៀបធៀបជាមួយនឹង«ព្រះលឹង្គ» ដោយអាទិ-ត មានន័យដើមថា ព្រះលឹង្គ) អាទិ-ទេវ មានន័យដើមថា «ទេវា ឬ ទ្វារ» ឬព្រះស្រី ទៅជាឡាតាំងថា Théo, ទៅជាបារាំងថា Dieu) ។ ភស្តុតាងដ៏ធំបំផុតដែកបានបង្ហាញថា ព្រះចាមនិងព្រះខ្មែរជាព្រះតែមួយ គឺគ្រាន់តែមានដូរឈ្មោះពីអក្សរ «រ» មកអក្សរ «ល» ប៉ុណ្ណោះ ៖ គឺព្រះអារី-អារ៉ា នៅអង្គរវត្ត (ហរិ ហរៈ ឡាយ៉ា - ព្រះនរាយ និងព្រះឥសូរបង្កើតលោក) ដែលបានក្លាយទៅជាព្រះចាម «អាលី-អាឡាហ៍-អាឡោះ-អាល័យ» បង្កើតលោកដូចគ្នា ។

⌘

⌘ ⌘

★★★ជាឧទាហរណ៍តូចមួយ (នៃជនជាតិយួនជាប្រជាជនភាគតិច) នៅក្នុងឆ្នាំ១៧៧២ ចិនកន្តាំងម្នាក់ឈ្មោះ ម៉ាក់គូ ដែលរកស៊ីមានបាន ដោយបើកបនល្បែងនៅភ្នំពេញ ក៏បានទៅតាំងខ្លួនធ្វើជាមេចោរចិននៅស្រុកពាម ហើយក៏បានប្លន់រឹបអូសខេត្តខ្មែរចំនួន៦ យកទៅថ្វាយស្តេចអណ្ណាម មានស្រុកពាម (យួនហៅហាទៀង), «ស្រែលួងកែ» (កែឬកាអ៊ី ក្នុងភាសាខ្មែរដើមគឺជាព្រះឥសូរ) ឬស្រែអំបិល, «រូងធំ» (កំពង់សោម) កាលពីដើមមានឈ្មោះថា ក្រមួន-ស, «កាន់-វ៉ុត» (កំពត), កាម៉ៅ, កាលពីដើមឈ្មោះថាទឹកខ្មៅ នៅភូមិភាគខាងត្បូង ។ (យោងតាមសាវតានៃប្រទេសកម្ពុជា របស់លោក Adhémard Leclère) ។

★★★នៅក្នុងអត្ថបទមួយរបស់ព្រះចៅអង្គឌួង ផ្ញើទៅព្រះអធិរាជ ណាប៉ូឡេអុងទី៣ កាលពីឆ្នាំ១៨៥៣ មានសេចក្តីដូច្នេះថា ៖ «ខេត្តកម្ពុជាដែលជនជាតិអណ្ណាមបានប្លន់យកទៅមាន ដូងណាយ ដែលត្រូវប្លន់យកទៅចំនួនជាង២០០ឆ្នាំមកហើយ ។ ប៉ុន្តែមានខេត្តច្រើនទៀតណាស់ ដែលយួនទើបនឹងប្លន់យកទៅថ្មីៗ គឺ សៃគ្គង, លង់ហោរ, ផ្សារដែក, មី-ថ, ព្រះត្រពាំង, អុងម៉រ, ក្រមួន-ស, ទឹកខ្មៅ, ពាមឬហាទៀង, កោះត្រល់ និងកោះត្រឡាច» ហើយព្រះអង្គឌួងក៏ធ្វើសេចក្តីអង្វរករទៅស្តេចបារាំង បែបដូចជាថា ៖ «ប្រសិនបើដោយចៃដន្យ ជនជាតិអណ្ណាមលើកខេត្តណាមួយក៏ដោយក្នុងតំបន់ទាំងនេះ ទៅថ្វាយព្រះកូណា, សូមព្រះអង្គកុំទទួលយកឲ្យសោះ ពីព្រោះគឺជាខេត្តរបស់ខ្មែរ ។ ខ្ញុំសូមឲ្យព្រះកូណាមានសេចក្តីអាណិតអាសូរចំពោះរូបខ្ញុំនិងប្រជាពលរដ្ឋរបស់ខ្ញុំផង ដើម្បីកុំឲ្យមានការបាត់បង់តទៅទៀត និងដើម្បីកុំឲ្យយើងដាច់ខ្យល់ស្លាប់នៅក្នុងព្រះរាជាណាចក្រសព្វថ្ងៃដែលនៅរួមតូចមួយក្រវិច» (ស្រង់ចេញពីសៀវភៅ «Les Frontières du Cambodge» par Sarin Chhak, p.152) ។

★★★ យោងតាមលិខិតព្រះអង្គឌួង «ដូងណាយ» ជាខេត្តខ្មែរ ដែលបានធ្លាក់ទៅក្នុងកណ្តាប់ដៃយួនជាយូរមកហើយ...ដូច្នេះសូមអានអត្ថបទមួយរបស់លោក Adhémard Leclère ទាក់ទងនឹងតំបន់ដូងណាយ ៖

«គឺនៅក្នុងពេលនោះហើយ ក្នុងកំឡុងឆ្នាំ១៦៨០ មានឧត្តមសេនិយចិនម្នាក់ឈ្មោះ ដួង-ង៉ាន់ឌិច ដែលជាក្រុមបក្សរបស់ស្តេចមីង ដែលបានប្រយុទ្ធចាញ់កងទ័ពរបស់ ខាំងហ៊ី, ព្រះអធិរាជថ្មីនៃរាជវង្សថាញ់, បានបញ្ជាឲ្យកងទ័ពខ្លួន ចុះសំពៅចំនួន២០០ ឆ្លងកាត់ខ្យល់ព្យុះសមុទ្រ ឆ្ពោះទៅប្រទេសអណ្ណាម ។ ដោយនៅសល់សំពៅតែ៥០ ហើយនិងមនុស្សតែ៣,០០០នាក់ប៉ុណ្ណោះ នៅពេលទៅដល់ច្រាំងអណ្ណាម ឧត្តមសេនិយរូបនេះ ក៏ធ្វើដំណើរទៅ ទួរ៉ាន ទៅសុំដីជំរកស្នាក់នៅចំពោះស្តេចយួន ។ ព្រះចៅអណ្ណាម ដោយមិនចង់បានជនបរទេសទាំង៣,០០០នាក់នៅក្បែរខ្លួន ហើយដោយមិនបានភ្លេចបញ្ជូនដំណឹងនេះទៅព្រះជ័យជេដ្ឋា (ទី៤) ក៏បានបញ្ជូនជនជាតិចិនទាំងនេះ ឲ្យទៅរស់នៅក្នុងទឹកដីខ្មែរ នៅក្នុងខេត្ត បារីយ៉ា និងដូងណាយ (Dâung-Nay) ដែលនៅទីនោះមានជនអន្តោប្រវេសន៍យួន ដែលគោរពតែស្តេចយួនចុះមកនៅខ្លះៗហើយៗដែលចាត់ទុកទឹកដីខ្មែរជាទឹកដីរបស់ខ្លួន ។ ឧត្តមសេនិយចិន ដួង-ង៉ាន់ឌិច ដោយមិនសប្បាយចិត្តនឹងទឹកដីដែលស្តេចយួនលើកឲ្យ ក៏បានជ្រើសរើសយកមី-ថ ហើយតាំងនៅទីនោះជាមួយនឹងទ័ពពាក់កណ្តាលរបស់ខ្លួន ។ ចំណែកទ័ពពាក់កណ្តាលទៀត ជាមួយនិងមេទ័ពរង ត្រាំង ក៏បានសំរេចរស់នៅក្នុងទឹកដីដែលស្តេចយួនចែកឲ្យនៅបារីយ៉ា (បារីយ៉ា, បារ៉ាយ, ភរិយា... ពាក្យខ្មែរដើមមានន័យថា ព្រះអារិយ៉ា, គឺជាដែនដីដែលព្រះសូរិយ៉ាចងដៃ) ។

«ពួកចិនអស់ទាំងនេះ ក៏មានការស៊ីគ្រលុំត្រូវរ៉ូវគ្នាជាមួយនិងពួកអណ្ណាមមួយរំពេជ ព្រោះជាជនបរទេសដូចគ្នា ព្រមទាំងមិនសូវចុះសំរុងនឹងជនជាតិខ្មែរហើយនិងអាជ្ញាធរខ្មែរ ដែលគ្រប់គ្រងតាងនាមស្តេចខ្មែរនោះទេ ។ ម្យ៉ាងវិញទៀត ពួកគេចូលចិត្តអំពើហឹង្សាកាប់ចាក់... មិនសូវរាប់អានបំពេញកិច្ចការងារ ហើយលើសពីជនជាតិអណ្ណាមទៅទៀត មិនព្រមគោរពច្បាប់គ្រប់គ្រងនៃព្រះរាជាណាចក្រខ្មែរនោះទេ ។ ពួកគេរស់នៅជាក្រុមចោរ ហើយមិនអាចចាត់ទុកថាជាប្រជាជនបានទេ ដោយពួកនេះនៅតែនឹកស្រណោះសង្គ្រាមដែលគេធ្លាប់បានធ្វើពីអតីតកាល ម្ល៉ោះហើយពួកគេមិនសូវជាស្រឡាញ់ពេញចិត្តនឹងសន្តិភាព ដែលពួកគេបានជួបប្រទះនៅប្រទេសកម្ពុជានោះទេ (ស្រង់ចេញពី Histoire du Cambodge p.356) ។

★★★ យោងតាមអត្ថបទខាងលើនេះ ខ្ញុំបានសង្កេតឃើញថា ពួកជនជាតិយួន ជាប្រជាជនភាគតិច ជាពូជរបស់ចិន (ពួកម៉ុងហ្គោល) ដែលបានចាញ់សង្គ្រាមនៅប្រទេសចិន ដូចជាជនឈ្មោះ ម៉ាក់គូ, ដួង-ង៉ាន់ឌិច, ត្រាំង... ហើយចុះមកតាំងនៅដែនដីចំប៉ា ហើយនិងកម្ពុជាក្រោម... រួចក៏ប្រើវិធីលេបទឹកដីទាំងនេះ ដោយល្បិចកលដូចដែលពួកម៉ុងគោ្គលធ្លាប់បានធ្វើនៅប្រទេសចិន គឺដោយបង្កើតសង្គ្រាមស៊ីវិលរវាងខ្មែរនិងខ្មែរ ពោលគេណ្ហទ័ពពីកម្ពុជាក្រោមមកវាយប្រហារពួកកម្ពុជាកណ្តាល ។

ខ្លួនខ្ញុំធ្លាប់ត្រូវមិត្តភក្តិជាច្រើន ហើយសូម្បីតែប្អូនបង្កើតក៏បានចោទថា ខ្ញុំជាជន«យល់សប្តិយលសូង» (A dreamer) ។ ពាក្យចោទនេះពិតជាត្រឹមត្រូវ ពីព្រោះខ្ញុំចេះតែស្រមើស្រមៃរវើរវាយថា «មហានគរខ្មែររស់ឡើងវិញ» ។ ក៏ប៉ុន្តែនៅក្នុងពេលសព្វថ្ងៃនេះ វាមានសញ្ញាច្រើនណាស់ដែលមិនអាចភូតភរបាន ហើយដែលបង្ហាញថា ដំណើរត្រឡប់វិលវិញនៃមហានគរកម្ពុជា គឺជារឿងមួយដែលមិនអាច

ឃាត់ឃាំងបាន (unstoppable!) ។

ទី១- ស្តេចខ្មែរសព្វថ្ងៃ (នរោត្តម-សីហនុ) ចុះពីពូជត្រសក់ផ្អែម ជាពូជព័រ, ពូជសំរែទន្សោងគោព្រៃ ខ្មែរលើនៅខេត្តព្រះវិហារ ។ ស្តេចសៀមចុះមកពីពូជខ្មែរនៅខេត្តតាកែវ ឬអង្គរបូរី... គឺពិតជាពូជខ្មែរក្រោម ។ ចំណែកអគ្គលេខាធិការនៃគណបក្សកុម្មុយនិស្ត ជាពួកព្រៃភ្នំ គឺជាពូជខ្មែរលើនៅដែនដីចំប៉ា ។ គឺជាសញ្ញាថា យួននិងសៀម ជាជនភាគតិចនៅក្នុងប្រទេសរបស់ខ្លួន (!!) ។

ទី២- នៅក្នុងពិភពលោកសព្វថ្ងៃ ទោះនៅទីកន្លែងណាក៏ដោយ ពួកជនរាតត្បាតគេកំពុងតែធ្វើដំណើរថយក្រោយ ។ ជាការដែលមិនគួរឲ្យជឿបាន នៅមជ្ឈិមបូព៌ា ពួកជនជាតិអ៊ីស្រាអែលកំពុងតែធ្វើការដកថយពីទឹកដីអារ៉ាប់ ដែលជាដែនដីរបស់អរិយជន ។ ប្រធានាធិបតីបច្ចុប្បន្ននៃប្រទេសឥណ្ឌូណេស៊ីកំពុងតែផ្តល់«ស្វ័យភាព» (លទ្ធិគ្រប់គ្រងខ្លួនដោយខ្លួនឯង) ទៅដល់ពួកបះបោរ«អច្ឆេះ» ដែលសុទ្ធសឹងតែជាពួកអរិយជនផងដែរ ។ ដូច្នេះតើមានប្រការអ្វី ដែលអាចទប់ទល់ជនជាតិយួន មិនផ្តល់«ស្វ័យភាពទៅដែនដីចំប៉ា ហើយនិងកម្ពុជាក្រោម?» ហើយតើមានប្រការអ្វីដែលអាចឃាត់ឃាំងពួកសៀម មិនផ្តល់ស្វ័យភាពទៅកម្ពុជាលើ ? (ដែនដីកម្ពុជាក្នុងសម័យជ័យវរ្ម័នទី៧ មានទល់ដែនខាងលិចជាប់នឹងជ្រោយម៉ាឡាកា ប្រទេសម៉ាឡេ, ខាងកើតជាប់និងសមុទ្រចិន, នៅខាងជើងជាប់ទន្លេសាឡ្វិននៃប្រទេសភូមា និងជាប់ព្រំប្រទល់នៃប្រទេសចិន) ។

ទី៣- ភូមិសាស្ត្រនៃប្រទេសយួនសព្វថ្ងៃ គឺជានាគរាជដែលវាត់កន្ទុយក្តោបក្តាប់ប្រទេសកម្ពុជា ។ ប៉ុន្តែ នារាជនេះត្រូវចិនវាយបែកក្បាល ពោលគឺខេត្តយួនដ៏សំខាន់៤ នៅជាប់នឹងព្រំដែនចិន ត្រូវខ្ទេចម៉ដ្ឋជាផេះតាំងពីខែកុម្ភៈ១៩៧៩ ។ កន្ទុយរបស់នាគរាជគ្មានកម្លាំងរុំព័ទ្ធប្រទេសកម្ពុជាបានទៀតទេ គឺត្រូវតែរលាយ ។ យួនធ្លាក់ខ្លួនក្រ ហើយត្រូវបណ្តាសាររបស់ពុទ្ធទំនាយ ៖ «អាកន្ទប ឱបកន្ទិន ស៊ីកន្ទក់ បក់កន្ទុយ នៅក្រោមដើមកន្ទួត» ។ ពួកមេដឹកនាំយួនសព្វថ្ងៃ មិនហ៊ានទៅស្រុកចិនទេ ពីព្រោះជំពាក់លុយចិន (២០ពាន់លានដុល្លារ) មិនហ៊ានទៅស្រុករុស្ស៊ីទេ ពីព្រោះជំពាក់លុយរុស្ស៊ី, មកបក់កន្ទុយនៅសហរដ្ឋអាមេរិក គ្មាននរណាមើល... គឺបានត្រឹមតែបក់កន្ទុយនៅក្រោមដើមកន្ទួតនៃប្រទេសកម្ពុជាទៅវិញ ។ ចំណែកសៀមកំពុងតែមានបញ្ហាយ៉ាងធ្ងន់ធ្ងរ នៅខេត្តខាងត្បូងបំផុត ដែលសៀមបានប្លន់ពីជនជាតិចាម-ម៉ាឡេជាង២០០ឆ្នាំមកហើយ ។ សៀមពុំមានដំណោះស្រាយអ្វីក្រៅពីការប្រគល់ស្វ័យភាព ទៅជនជាតិចាមតែប៉ុណ្ណោះ ហើយនៅក្នុងពេលជាមួយគ្នានោះក៏ត្រូវប្រគល់ស្វ័យភាព ទៅគ្រប់ខេត្តសៀមទាំងអស់ដែលជាខេត្តរបស់ខ្មែរ ។

⌘

⌘ ⌘

មិនមែនតែជនជាតិយួនទេ ដែលបានប្រើរូបសម្រស់របស់ស្រី មកបំពុលស្តេចខ្មែរ ដើម្បីរំលាយរាជវង្សនិងនគរខ្មែរ... ជនជាតិសៀម (ដែលជាពួកម៉ុងគ្រោល ចុះមកពីខេត្តយូណាន់ដូចគ្នា) ក៏បានប្រើកលល្បិចបែបដូចនេះមុនយួនទៅហើយ ។ ជនជាតិសៀមជាជនជាតិមួយ ដែលមានចិត្តច្រណែននិងអរិយធម៌របស់ក្រុងអង្គរខ្លាំងណាស់... ហើយមានគោលប្រាថ្នារំលើងឫសគល់នៃអរិយធម៌នេះតែម្តង ។ ក្នុងប្រការនេះ យើងមើលឃើញថា នៅពេលដែលស្តេចខ្មែរជ័យវរ្ម័នទី៧ កំពុងតែបង្កើនឫទ្ធានុភាពនិងកិត្យានុភាពជាស្តេចកំពូលភព នៅពេលនោះក៏មានកត្តានៃការស្រុតរលំនៃក្រុងអង្គរផងដែរ, គឺព្រះទេពីរបស់ទ្រង់ព្រះនាងឥន្ទ្រទេវី ដែលជាក្សត្រីកំពូលចេះដឹង និងជាគ្រូឧបជ្ឈាយ៍របស់ស្តេច បានណែនាំទ្រង់ឲ្យដូរលទ្ធិសាសនា, លែងគោរពសញ្ញាព្រះលឹង្គ (ព្រះលឹង្គនៅអង្គរវត្ត គឺជាសញ្ញានិមិត្តរូបនៃអក្សរ«ក»ឥតសក់) តែមកឲ្យគោរពរូបព្រះពោធិសត្វស្មឹងស្មាធ «វិបស្សនា» ហាវ៉ាលោកកេស្សរ៉ាវ៉ា (គឺជាព្រះឥសូរបង្កើតលោកដដែលគ្រាប់តែដូរតែឈ្មោះ) ។ ព្រះរាជាចូលវ័យចាស់ជរាក៏កើតមានជម្ងឺឃ្លង់... គឺជាស្តេចគំលង់ (ខ្មែរក្រោមហៅថា «កាឡុង» យួនហៅថា «កាឡុង» គឺជារោគស្រី), ម្លោះហើយព្រះអង្គចេះតែអាណិតខ្លួន ហើយត្រូវការដោះដូរឲ្យមានជំនឿថ្មី ។ ក៏ប៉ុន្តែសញ្ញាព្រះលឹង្គជាមូលដ្ឋាននៃអរិយធម៌ក្រុងអង្គរតែម្តង... ប្រការដែលស្តេចចូលសាសនាថ្មីដោយយកព្រះពុទ្ធអង្គមកជំនួសព្រះទេវរាជ្យ (ថ្វីត្បិតតែជាអ្នកមានបុណ្យដូចគ្នា) គឺជាប្រភពនៃជម្លោះរវាងខ្មែរនិងខ្មែរ ហើយដែលបណ្តាលឲ្យក្រុងអង្គរទាំងមូលវិនាសអន្តរាយ ក្លាយទៅជាផ្នូរខ្មោចនៃពួកអរិយជន ។ ព្រះនាងឥន្ទ្រទេវីច្បាស់ជាមិនមែនស្រីខ្មែរទេ... តែជាស្រីសៀមដែលមានគំនុំជាមួយនឹងពូជសាសន៍ខ្មែរ ។

បដិវត្តន៍ឬសង្គ្រាមស៊ីវិលបានផ្ទុះឡើងនៅសតវត្សរ៍ទី១៤ នៅក្រោមរាជ្យស្តេចជ័យវរ្ម័នទី៩ ហៅសីហនុ ព្រះបរម:ឥស្សរវ៉ារ៉ា (១៣២៧-១៣៣៦) ស្តេចដែលកាន់សាសនាព្រះសេវលឹង្គ... ចំណែកបណ្តាមុខមន្ត្រីកាន់លទ្ធិពុទ្ធនិយម ។ កាលនោះអ្នកយាមចំការត្រសក់របស់ស្តេច ឈ្មោះនាយ ឆាយ បានទទួលព្រះរាជបញ្ជាឲ្យពិឃាតដោយចោលលំពែង ទៅលើចោរពានវាំងឯណាក៏ដោយ ដែលហ៊ានប្រមាងចូល«ចំការត្រសក់ផ្អែម» ។

«នៅពេលក្រោយមក នៅក្នុងរាត្រីមួយដ៏សែនងងឹត ព្រះរាជាក៏ចុះទៅក្នុងចំការត្រសក់ ហើយក៏ត្រូវអ្នកយាមចំការម៉ៃច្រឡំថាជាចោរ ម៉ោះហើយព្រះរាជាក៏ត្រូវពិឃាតដោយលំពែងរបស់នាយឆាយនៅពេលនោះទៅ ។

«យោងតាមសេចក្តីតំណាលដែលមាននិយាយតៗគ្នា, ព្រះរាជបុត្រឈ្មោះច័ន្ទ បានយកធាតុរបស់ទ្រង់ទៅដម្កល់នៅប្រាសាទ «ប្រែរូប» (ប្រែរូបជាព្រះកាឡា, ព្រះនៃពេលវេលា ពោលគឺព្រះឥសូរ ឬព្រះសេវលឹង្គដដែល) ។ តាមពិតព្រះពុទ្ធជាអវតានៃព្រះឥសូរ ជាកូននិងឪពុក ក៏ប៉ុន្តែជនជាតិសៀមមានជោគជ័យក្នុងប្រការណែនាំឲ្យខ្មែរសម្លាប់ឪពុកខ្លួនឯង ! ។

«ពួកវរជននិងមន្ត្រីក៏បានរួមប្រជុំគ្នា ដើម្បីជ្រើសរើសស្តេចថ្មី សំរាប់ឡើងគ្រងរាជបល្ល័ង្ក ។ ពួកគេមិនបានធ្វើការផ្តន្ទាទោសទៅលើឃាតករ បែរជាលើកតម្កើងនាយឆាយ ឲ្យពាក់មកុដសោយរាជ្យ (ពីឆ្នាំ១៣៣៦ទៅ១៣៤១) ព្រមតាំងឲ្យរៀបអភិសេកជាមួយបុត្រីស្តេច ដើម្បីឲ្យមានលក្ខណ:ស្របច្បាប់» ។ (ស្រង់ចេញពី Histoire du Cambodge par A-Dauphin Meunier- p.52) ។

តាមពិតរឿងត្រសក់ផ្អែមជារឿងឆ្លៀលំអសំរាប់បន្ទរសម្បជញ្ញ:របស់នាយត្រសក់ផ្អែមប៉ុណ្ណោះ ។ ការពិឃាតស្តេចនេះ ជាបដិវត្តន៍ដ៏កាចសាហាវ ដែលកើតមានឡើងក្នុងព្រះរាជវាំងអង្គរ ។ នាយឆាយជាមេទ័ពរបស់ស្តេច ព្រមទាំងជាព្រះរាជសុណ្ហិសារផងដែរ... ចំណែកកូនស្រីរបស់ទ្រង់ បានលួចព្រះខ័ន្ធយកមកឲ្យប្តីដើម្បីពិឃាតឪពុករបស់ខ្លួនឯង ព្រមទាំងកាត់ដៃកាត់ជើងប្អូនប្រុសរបស់ខ្លួនឯងយកទៅញាត់គុក ព្រោះជាកូនស្តេចស្នងរាជ្យ ។

រាជវង្ស (ពុទ្ធនិយម) របស់តាត្រសក់ផ្អែម បានកើតចេញមកពីឧក្រិដ្ឋកម្មនិងការបង្ហូរឈាម ។ ម្លោះហើយជននេះក៏មានវិប្បដិសារីគ្រប់ជំហាន ។ បន្ទាប់មកទ្រង់បានរត់ទៅសាងផ្នួស ក្រោយពីបានសោយរាជ្យក្នុងរយ:ពេលតែ៤ឆ្នាំ ។

កូនរបស់តាឆាយឈ្មោះ ព្រះនិព្វនបាទ(សោយរាជ្យពីឆ្នាំ១៣៤០-១៣៤៦) គិតតែពីរឿងសេចក្តីស្លាប់មិងការចូលនិព្វន, លែងរវីរវល់នឹងការគ្រប់គ្រងព្រះនគរ គឺយករួចតែខ្លួនឯង ។ តាំងពីនោះមក ស្តេចខ្មែរលែងបានសាងសង់ប្រាសាទថ្មីអ្វីទៀតហើយ... មិនត្រឹមតែប៉ុណ្ណោះ បានបោះបង់ចោលនយោបាយទឹក ដែលអនុញ្ញាតឲ្យមានផលិតកម្មស្រូវ៣-៤ដងក្នុងមួយឆ្នាំ ដែលស្តេចវរ្ម័នពូជអំបូរព្រះសូរិយ៉ាធ្លាប់បានប្រារព្ធធ្វើចំនួន១៥សតវត្សរ៍មកហើយ ។

គឺជាការស្រុតចុះដែលគ្មានអ្វីទប់បាននៃអរិយធម៌ក្រុងអង្គរ។ ជាមួយនឹងការបាត់បង់នៃព្រះរាជវង្សព្រះអាទិត្យ នយោបាយសេដ្ឋកិច្ចនៃទីក្រុងនេះ ក៏បានដួលរលំទៅតាមគ្នា ។

«នៅពេលដែលគេលែងទំនប់ដើម្បីចែកទឹកជាអចិន្ត្រៃយ៍ទៅលើភ្លឺស្រែ, ផលិតកម្មមួយឆ្នាំ៣-៤ដង ក៏ត្រូវរួញមកនៅតែមួយដង ។ កាលណាផលិតកម្មស្រុតចុះ កំណើនប្រជាជនក៏ត្រូវអន់ថយ ។ ក្នុងពេលជាមួយគ្នានោះ បរាជ័យនៃសឹកសង្គ្រាម និងការចាប់ប្រមូលប្រជាជនខ្មែរជាឈ្លើយ ពីសំណាក់ពួកសៀម បណ្តាលឲ្យសភាពការណ៍រឹតតែធ្ងន់ធ្ងរ» (ស្រង់ចេញពីសំណេររបស់លោក Bernard Philippe Groslier) ។

គឺនៅក្នុងរាជ្យ ព្រះលំពង់ ចៅរបស់តាត្រសក់ផ្អែម (១៣៤៦-១៣៥១) ដែលស្តេចសៀម រាមាធិបតី ធ្វើការវាយប្រហារដោយចំហទៅលើទីក្រុងអង្គរ ។

«នៅក្នុងឆ្នាំ១៣៥០, ស្តេចនៅសុក្ខោតៃ, រាមាធិបតី បានលើករាជធានីមកតាំងនៅលើកោះមួយនៃទន្លេមេណាម ក្បែរព្រំប្រទល់នៃប្រទេសកម្ពុជា គឺអយុធ្យា ដែលក្លាយទៅជារាធានីរបស់សៀមរហូតដល់ឆ្នាំ១៧៦៨ ។ ការផ្លាស់ប្តូររាជធានីនេះបង្ហាញនូវគោលបំណងច្បាស់លាស់របស់ស្តេចសៀម ៖ គឺវាតត្បាតប្រទេសកម្ពុជា បើប្រទេសនេះមិនព្រមធ្វើការចំណុះចុះចូល ។ នៅក្នុងឆ្នាំ១៣៥១ រាមាធិបតីក៏បានសំរេចចិត្តលោតចូលប្រឡូក ។ ស្តេចនេះបានកេណ្ឌកងទ័ពប្រយុទ្ធពីរកង ។ (កកន ៖ ពីក្នុងដីខ្មែរយកទៅសម្លាប់ខ្មែរ, គឺដូចគ្នានឹងល្បិចកលរបស់ជនជាតិយួននៅទិសខាងកើត ៖ សង្គ្រាមសាសនាក៏បានក្លាយទៅជាសង្គ្រាមវាតទឹកដី !) ។ ស្តេចសៀមក៏បានវាយឆ្មក់ទៅលើបន្ទាយពីររបស់ខ្មែរនៅតាមព្រំប្រទល់ ហើយក៏ធ្វើដំណើរឆ្ពោះទៅអង្គរ ។ ដោយត្រូវពួកខ្មែរប្រយុទ្ធទប់ទល់ នៅត្រង់កំពែងរាជធានីតែម្តង ទ័ពសៀមក៏វិលត្រឡប់បកក្រោយ ។ នៅពេលដែលស្តេចលំពង់រាជានឹកស្មានថាបានទទួលជោគជ័យ ដោយធ្វើការរំសាយកងទ័ព ព្រមទាំងបញ្ឈប់កំណែនទ័ព ដែលទ្រង់ទើបបានបញ្ជាពីពេលមុននេះបន្តិច, ស្តេចសៀមជាខ្មាំងសត្រូវ ក៏បន្ថែមទ័ពមួយកងទៀត ទៅលើទ័ពពីរកងលើកមុន ហើយក៏ចាប់ផ្តើមវាយលុកចូលក្នុងក្រុងអង្គរជាថ្មី ។

«ការឡោមព័ទ្ធបានប្រព្រឹត្តទៅអស់ជាង១ឆ្នាំ ដែលនៅក្នុងពេលនោះ ព្រះលំពង់រាជាក៏បានចូលមរណកាលដោយរោគាពាធ ។ ការប្រយុទ្ធតស៊ូក៏ត្រូវធ្វើបន្តទៅទៀត ក្រោមការដឹកនាំនៃអនុជម្នាក់របស់ទ្រង់ ។ គេឮតែសំរែកទួញយំរបស់ប្រជាជន ។ ពួកឧត្តមសេនិយ ពួកមេទ័ពទាំងឡាយត្រូវដេកដួលស្លាប់ម្នាក់ម្តងៗ ។ សូម្បីតែសត្វស្លាប ក៏បញ្ចេញសំរែកដ៏អភ័ព្វរបស់ខ្លួននៅក្នុងទីក្រុង ដែលគេឡោមជុំជិត», នេះជាសេចក្តីដំណាលរបស់ព្រះរាជពង្សាវតាខ្មែរ ( កកន ៖ ស្តាប់ៗទៅ ការរលត់រលាយនៃទីក្រុងអង្គរ ក៏ដូចការរលត់រលាយនៃទីក្រុងភ្នំពេញ ក្នុងសម័យខ្មែរសាធារណរដ្ឋ !) ។ រាមាធិបតី ( កកន ៖ ស្តេចសៀមដែលបញ្ចូលលទ្ធិពុទ្ធនិយមទៅក្រុងអង្គរ នៅរក្សាឈ្មោះខ្លួនឯងជាព្រះឥសូរធិបតី ហើយមកប្រកបមុខរបរបង្ហូរឈាមជាតិខ្មែរជាត្រីមុខ ។ ពួកម៉ុងគ្គោលសៀមយួន ជាទមិឡឥតសាសនាដូចគ្នា ។ ពួកវាគ្មានជំនឿអ្វីទេ ពីព្រោះពួកវាយកសាសនាធ្វើជាឈ្នាន់!) ស្តេចសៀមរាមាធិបតី ដឹកនាំការប្រយុទ្ធដោយខ្លួនឯងផ្ទាល់ ។ ទ្រង់បានកំចាត់កងទ័ពខ្មែរជំនួយ ដែលមកវាយបំបែកការឡោមព័ទ្ធ ។ នៅតាមទីរួមខេត្ត ទ្រង់ក៏បានបញ្ជាឲ្យបំបែកកងទ័ពខ្មែរ ដែលកេណ្ឌឡើងដោយប្រញាប់ប្រញាល់ ។ នៅទីបញ្ចប់ បន្ទាប់ពីធ្វើការស្ទង់ស្ទាបនូវចំណុចខ្សោយជាច្រើនកន្លែងនៃការតស៊ូ ស្តេចសៀមក៏បញ្ជាឲ្យមានការវាយលុកពីគ្រប់ច្រកល្ហក ។ នៅទីបំផុត ទ្វារខាងកើតក៏ត្រូវរបើក ។ នៅក្នុងទីក្រុងមានការប្រយុទ្ធគ្នា នៅតាមផ្លូវថ្នល់ ។ ( កកន ៖ ការរបើកទ្វារខាងកើត គឺច្បាស់ជាមានជនជាតិខ្មែរក្បត់ ធ្វើការឲ្យសៀម !!)...

«ពួកយុទ្ធជនខ្មែរបីបួនរូប ដែលជាអ្នកថែរក្សាព្រះខ័ន្ធមាសនិងលំពែងរបស់នាយឆាយ សំរាប់ព្រះរាជវង្សថ្មី ក៏បានឱបខ្ចប់របស់ជាទីសក្ការៈទាំងនេះ រត់គេចដោយឆ្លងកាត់ជួរខ្មាំងសត្រូវ ។ ក៏ប៉ុន្តែព្រះរាជធានីទាំងមូលបានធ្លាក់ចូលក្នុងកណ្តាប់ដៃសៀមរួចទៅហើយ ។

«រាមាធិបតីក៏ចាប់ប្រមូលប្រជាជនអង្គរភាគច្រើន ទៅធ្វើជាខ្ញុំបំរើដាច់ថ្លៃ ( កកន ៖ សៀមឲ្យរួចខ្លួនតែពួករនុកក្នុងប៉ុណ្ណោះ) ។ ទ្រង់បានប្រមូលយកមាសនិងប្រាក់ពីព្រះរាជវាំងនិងពីប្រាសាទនានា ហើយក៏ដាក់ខេត្តខ្មែរឲ្យនៅក្រោមការគ្រប់គ្រងនៃក្រុមគ្រួសារទ្រង់» ។ (ដកស្រង់ចេញពី Histoire du Cambodge par A-Dauphin Meunier- p.56-57) ។

⌘

⌘ ⌘

«ប្រាសាទសិលា កំបាំងកណ្តាលព្រៃ គួរឲ្យស្រមៃ នឹកដល់យសស័ក្តិ មហានគរ ជាតិខ្មែរដូចថ្ម គង់វង់នៅល្អ រឹងប៉ឹងជំហរ យើងសង្ឃឹមពរ ភ័ព្វព្រេងសំណាងរបស់កម្ពុជា មហារដ្ឋ កើតមានយូរអង្វែងហើយ» បទនគររាជ តែងដោយសម្តេចសង្ឃជួន-ណាត ។

★★★ នៅក្នុងសតវត្សទី១៩ ក្រុងអង្គក៏បានធ្លាក់ចូលទៅក្នុងសករាជសូន្យ ។ នៅពេលដែលជនជាតិបារាំង Mouhot បានរកឃើញអង្គរនៅក្នុងដីសៀម... គឺជាទីកន្លែងរហោដ្ឋានមួយដែលគ្មានមនុស្សនៅ ។ លោក Mouhot នឹកស្មានថា អង្គរជា«ផ្នូរខ្មោចដ៏មហាសំបើមធំធេងនៃជនជាតិសាសន៍មួយ ដែលរលត់រលាយទៅគ្មានពេលវិលត្រឡប់» ។ ( Mouhot ៖ «Il me sembla que se dessinait les contours gigastesques du tombeau de toute une race morte» ) ។

ទីក្រុងអង្គរដែលធ្លាប់មានប្រជាជនខ្មែរពីរលាននាក់រស់នៅក្នុងសម័យអតិតកាល ក៏បានត្រូវជនជាតិសៀម ដែលវាច្រណែនខ្មែរ យកទៅបង្កប់ចោលក្នុងព្រៃប្រឹក្សព្រលតាវល្លិ ជាមហាផ្នូរខ្មោច ។ ទើបតែក្នុងពេលថ្មីៗនេះទេ ដែលជនជាតិសៀមស្រែកស្តាយស្រណោះ ដោយចោទថា ជនជាតិខ្មែរលួចអង្គរវត្តរបស់ពួកវា ប្រៀបបាននឹងរឿងកុន «យក្សដែក» អាមេរិកាំង The Terminator កាលណាដួងកែវនៅមានពន្លឺ ក៏យក្សដែកនៅតែរស់ ហើយប្រមូលកម្លាំងបានឡើងវិញ ។ ចំណែកអង្គរ គឺជាដួងកែវរបស់មហារដ្ឋកម្ពុជា កាលណាអង្គរនៅមានពន្លឺ គឺមហាយក្សខ្មែរនៅតែរស់ ដូចសង្ឃដីការបស់សម្តេចជួន-ណាត ៖ «ជាតិខ្មែរដូចថ្ម គង់វង់នៅល្អ រឹងប៉ឹងជំហរ !» ។

ក្រុងសៀមរាបអង្គរសព្វថ្ងៃ ជាសម្បត្តិវប្បធម៌របស់ពិភពលោកទាំងមូល ជារដ្ឋធានីនៃអាស៊ីអាគ្នេយ៍ ទាំងផ្នែកសិល្បៈ, ឧស្សាហកម្ម (ទេសចរណ៍) និងពាណិជ្ជកម្ម ។ មហានគរខ្មែរ កំពុងតែរស់ឡើងវិញហើយ (!!) ។